ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ...២៤៨...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតគណៈកម្មាធិការអន្តរក្រសួងសម្រាប់គម្រោងអភិវឌ្ឍន៍លំនៅឋានតម្លៃសមរម្យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើតគណៈកម្មាធិការអន្តរក្រសួងសម្រាប់គម្រោងអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ ដែលសរសេរជាអក្សរកាត់ថា "**គ.អ.ល.**" ដើម្បីអនុវត្ត "គោលនយោបាយស្ដីពីការលើកទឹកចិត្ត និងការបង្កើតកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ" ពាក់ព័ន្ធនឹងការលើកទឹកចិត្តផ្នែកសារពើពន្ធ ផ្នែកវិនិយោគសាធារណៈ និងនិយ័តកម្ម ប្រកបដោយប្រសិទ្ធភាព សម្ពាភាព និងភាពប្រកួតប្រជែង។

## ជំពូកទី២
## សមាសភាពនិងភារកិច្ច

**មាត្រា២.-**

**គ.អ.ល.** មានសមាសភាពដូចខាងក្រោម÷

| | |
|---|---|
| ១- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| ៣- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៤- ប្រធានក្រុមការងារបច្ចេកទេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥- ប្រធានក្រុមការងារបច្ចេកទេសក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |

សមាសភាពជាក់ស្ដែងនៃ **គ.អ.ល.** ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា៣.-**

**គ.អ.ល.** មានភារកិច្ច ដូចតទៅ÷

- ពិនិត្យ និងពិភាក្សាលើសំណើគម្រោងអភិវឌ្ឍន៍លំនៅឋានសមរម្យ ដើម្បីស្នើសុំការសម្រេចរបស់រាជរដ្ឋាភិបាល
- អនុម័តលើគោលការណ៍ណែនាំ និងនីតិវិធីនៃការរៀបចំ ពិនិត្យ អនុវត្ត និងគ្រប់គ្រងគម្រោងអភិវឌ្ឍន៍លំនៅឋានសមរម្យ
- កំណត់របៀបវារៈក្នុងដំណើរការតាមដាន និងត្រួតពិនិត្យ តាមដំណាក់កាលនីមួយៗនៃការអនុវត្តគម្រោង
- រៀបចំយុទ្ធសាស្ត្រទាក់ទាញដៃគូវិស័យឯកជនចូលរួមក្នុងកម្មវិធីអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ និង
- បំពេញតួនាទីជាអ្នកនាំពាក្យ ឬ ទំនាក់ទំនងសាធារណៈក្នុងការផ្សព្វផ្សាយ និងឆ្លើយតបចំពោះវិនិយោគិនសក្ដានុពលក្នុងនាមរាជរដ្ឋាភិបាល។

## ជំពូកទី៣
## ដំណើរការការងារ

**មាត្រា៤.-**

សមាសភាព **គ.អ.ល.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានអាចកោះអញ្ជើញ និងដឹកនាំការប្រជុំ **គ.អ.ល.** តាមការប្រគល់សិទ្ធិរបស់ប្រធាន។

**គ.អ.ល.** មានរបបប្រជុំសាមញ្ញ ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ព្រមទាំងអាចប្រជុំជាវិសាមញ្ញ តាមការចាំបាច់។

**គ.អ.ល.** មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ដំណើរការងាររបស់ខ្លួន។

**មាត្រា៥.-**

**គ.អ.ល.** អាចស្នើសុំកិច្ចសម្របសម្រួល និងសហប្រតិបត្តិការពីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យ និងផ្ដល់យោបល់លើការពិនិត្យ និងវាយតម្លៃគម្រោងអភិវឌ្ឍន៍លំនៅឋានតម្លៃសមរម្យ។

**មាត្រា៦.-**

**គ.អ.ល.** មានក្រុមការងារបច្ចេកទេសពីរជាសេនាធិការ រួមមាន ក្រុមការងារបច្ចេកទេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមការងារបច្ចេកទេសក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន។

ក្រុមការងារបច្ចេកទេសក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្រុមការងារបច្ចេកទេសក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៧.-**

**គ.អ.ល.** មានលេខាធិការដ្ឋានមួយ ដែលមានភារកិច្ចជួយសម្របសម្រួល និងផ្តល់ការគាំទ្រដល់ក្រុមការងារបច្ចេកទេសទាំងពីរ ក្នុងការបំពេញតួនាទីជាសេនាធិការ ជូនគណៈកម្មាធិការអន្តរក្រសួងសម្រាប់គម្រោងអភិវឌ្ឍន៍លំនៅឋានតម្លៃសមរម្យ។

កិច្ចដំណើរការ និងសមាសភាពនៃលេខាធិការដ្ឋាននេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃ សុក្រ ១២ កើត ខែ បុស្ស ឆ្នាំរកា ព.ស. ២៥៦១
ត្រូវនឹងថ្ងៃទី ២៩ ខែ ធ្នូ គ.ស. ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**អូន ព័ន្ធមុនីរ័ត្ន**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**